Forte
General Insurance



# បណ្ណសន្យារ៉ាប់រងយានយន្ត

## ខ និងលក្ខខណ្ឌសង្ខេបនៃ បណ្ណសន្យារ៉ាប់រងយានយន្តឯកជន និង យានយន្តអាជីវកម្មរបស់ក្រុមហ៊ុន ហ្វតតេ អ៊ិនស្ហួរ៉ិនស៍ (ខេមបូឌា)

សម្រាប់យានយន្ត ដែលជាកម្ចីពីអិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**បណ្ណសន្យារ៉ាប់រង ទោចក្រយានយន្ត មានការធានាដូចខាងក្រោម៖**

**1. ភារៈទទួលខុសត្រូវតាមផ្លូវច្បាប់លើតតិយជន (ភាគីទីបី) ៖**

ហ្វតតេ ផ្តល់នូវការធានាលើការចំណាយដែលលោកអ្នកត្រូវមានភារៈទទួលខុសត្រូវតាមផ្លូវច្បាប់ ដែលបណ្តាលមកពីគ្រោះថ្នាក់ដែលបង្ក ឬកើតឡើងដោយយានយន្តឯកជន ឬយានយន្ត អាជីវកម្មដែលត្រូវបានធានារបស់លោកអ្នក សម្រាប់៖

- ការបង្កឱ្យបាត់បង់ជីវិត ឬរបួសរូបរាងកាយរបស់តតិយជន
- ការបង្កឱ្យខូចខាតទ្រព្យសម្បត្តិរបស់តតិយជន

**កម្រិតនៃសំណងធានារ៉ាប់រង៖**

- អតិបរមា 10,000 ដុល្លារអាមេរិក ក្នុងម្នាក់ និងក្នុងមួយករណីសម្រាប់មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ ឬរបួសស្នាមលើរូបរាងកាយរបស់តតិយជន
- អតិបរមា 10,000 ដុល្លារអាមេរិក ក្នុងម្នាក់ និងក្នុងមួយករណីសម្រាប់ការខូចខាតទ្រព្យសម្បត្តិរបស់តតិយជន
- អតិបរមា 1,500 ដុល្លារអាមេរិក សម្រាប់សេវាផ្នែកច្បាប់
- អតិបរមា 100,000 ដុល្លារអាមេរិក សម្រាប់សំណងធានារ៉ាប់រងសរុបក្នុងមួយករណីគ្រោះថ្នាក់ ឬច្រើនករណីគ្រោះថ្នាក់ ក្នុងរយៈពេលធានារ៉ាប់រងមួយ។

**2. ចោរកម្ម និងការខូចខាតយានយន្តដែលត្រូវបានធានា (ការខូចខាតទាំងស្រុង និងការខូចខាតទាំងស្រុងតាមការសន្មត)៖**

ហ្វតតេ ផ្តល់នូវការធានាលើការបាត់បង់ ឬខូចខាតលើយានយន្តដែលត្រូវបានធានារបស់លោកអ្នក ដែលបណ្តាលមកពី ទឹកជំនន់ ព្យុះ រញ្ជួយដី ការផ្ទុះមីន និងចោរកម្ម (ចោរគាស់ ចោរលួច ចោរប្លន់យានយន្តទាំងមូល) ដែលកើតឡើងក្នុង ព្រះរាជាណាចក្រកម្ពុជា។

**កម្រិតនៃសំណងធានារ៉ាប់រង៖**

- **សម្រាប់ការខូចខាតយានយន្តមួយផ្នែក៖** សំណងជាការជួសជុលឬផ្លាស់ប្តូរគ្រឿងបន្លាស់នៃយានយន្ត ដើម្បីធ្វើឱ្យដូចដើមវិញនៅយានដ្ឋានដៃគូររបស់ហ្វតតេ ហើយលោកអ្នកត្រូវបង់ "កម្រិតមិនធ្វើសំណង(ទំនួលខុសត្រូវរបស់លោកអ្នក)" មកកាន់ ហ្វតតេ វិញ។
- **សម្រាប់ការខូចខាតយានយន្តទាំងស្រុង(ដែលមិនអាចជួសជុលបាន) និងករណីចោរកម្ម (ចោរគាស់ ចោរលួច ចោរប្លន់)៖** សំណងជាទឹកប្រាក់ធានារ៉ាប់រងត្រូវដកចេញនូវកម្រិតមិនធ្វើសំណង ដូចមានចែងក្នុងបណ្ណសន្យារ៉ាប់រង។ បន្ទាប់ពីការទូទាត់សំណងលោកអ្នកត្រូវប្រគល់កម្មសិទ្ធយានយន្តមកកាន់ ហ្វតតេ ដោយប្រគល់អោយ ហ្វតតេ នូវឯកសារពាក់ព័ន្ធទាំងឡាយ។
    - ប្រសិនបើទឹកប្រាក់ធានារ៉ាប់រងតូចជាង ឬស្មើ 60% នៃតម្លៃយានយន្តនោះ ហ្វតតេ នឹងទូទាត់សំណងតាមតម្លៃនៃការជួសជុលជាក់ស្តែងដោយត្រូវដកចេញនូវកម្រិតមិនធ្វើសំណង ហើយយានយន្តនោះនឹងនៅតែជាកម្មសិទ្ធិរបស់លោកអ្នក។
    - ប្រសិនបើទឹកប្រាក់ធានារ៉ាប់រងច្រើនជាង 60% នៃតម្លៃយានយន្តនោះ ហ្វតតេ នឹងទូទាត់សំណងតាមតម្លៃនៃការជួសជុល ជាក់ស្តែង ដោយត្រូវដកចេញនូវកម្រិតមិនធ្វើសំណង ហើយយានយន្តនោះ នឹងត្រូវប្រគល់មកជាកម្មសិទ្ធិរបស់ ហ្វតតេ ដោយភ្ជាប់មកជាមួយនឹងឯកសារពាក់ព័ន្ធនានា។

***សំណងច្រើនបំផុតសម្រាប់ករណីខាងលើ គឺស្មើនឹងទឹកប្រាក់ធានារ៉ាប់រងដូចដែលមានចែងក្នុងបណ្ណសន្យារ៉ាប់រងរបស់លោកអ្នក។**

**អត្ថប្រយោជន៍បន្ថែម៖**

ហ្វតតេ ផ្តល់ជូនលោកអ្នកនូវអត្ថប្រយោជន៍បន្ថែម ដូចខាងក្រោម៖

- **ការសណ្តោងយានយន្ត៖** សំណងតាមការចំណាយជាក់ស្តែង (ប៉ុន្តែមិនឱ្យលើសពីចំនួន 150 ដុល្លារអាមេរិក) លើការសណ្តោងយានយន្តទៅកាន់យានដ្ឋានដែលជិតបំផុត នៅពេលដែលយានយន្តនោះមិនអាចប្រើប្រាស់បានបន្ទាប់ពីគ្រោះថ្នាក់។
- **ការជួសជុលឬផ្លាស់ប្តូរកញ្ចក់៖** សំណងតាមការចំណាយជាក់ស្តែងលើការជួសជុល ឬផ្លាស់ប្តូរកញ្ចក់មុខ ឬកញ្ចក់បង្អួចនៃយានយន្តដែលការខូចខាតនេះ មិនបានធ្វើឱ្យមានការខូចខាតទៅកន្លែងផ្សេងទៀតនៃយានយន្តឡើយ អត្ថប្រយោជន៍នេះគឺ សម្រាប់ការខូចខាតតែ ១ដងប៉ុណ្ណោះ ក្នុងអំឡុងពេលធានារ៉ាប់រង ១ឆ្នាំ។ (ប្រសិនបើលោកអ្នកបានទាមទារសំណងម្តងរួចហើយលោកអ្នកអាចស្នើសុំអត្ថប្រយោជន៍នៃការជួសជុល ឬផ្លាស់ប្តូរកញ្ចក់នេះម្តងទៀតសម្រាប់ក្នុងអំឡុងពេលធានារ៉ាប់រង 1ឆ្នាំដែលបាន ដោយធ្វើការទំនាក់ទំនងមកកាន់ហ្វតតេតាមលេខទំនាក់ទំនងនៅចុងខិត្តបណ្ណនេះ។)

Forte
General Insurance

◆ **ករណីមិនធានា សំខាន់ៗ៖**

ហ្វតតេ នឹងមិនទូទាត់សំណងធានារ៉ាប់រងឡើយ លើរាល់គ្រោះថ្នាក់ ការបាត់បង់ ការខូតខាត និងភារៈទទួលខុសត្រូវតាមផ្លូវច្បាប់ (ដោយផ្ទាល់ ឬមិនផ្ទាល់ក្តី) ដែល៖

1. លោកអ្នកមិនបានរាយការណ៍ដល់ហ្វតតេក្នុងរយៈពេល 24 ម៉ោងក្រោយពេលកើតហេតុ។
2. លោកអ្នកមិនបានរាយការណ៍ដល់សមត្ថកិច្ចមូលដ្ឋានសម្រាប់ការបាត់បង់ដោយចោរកម្ម។
3. គ្រោះថ្នាក់នោះកើតឡើងនៅក្រៅទីតាំងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។
4. គ្រោះថ្នាក់នោះកើតឡើងខណៈ យានយន្តដែលត្រូវបានធានា៖
   - ត្រូវបានប្រើប្រាស់ខុសពីលក្ខខណ្ឌដែលបានកំណត់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។
   - ត្រូវបានបើកដោយអ្នកបើកបរដែលគ្មានការអនុញ្ញាតបើកបរពីអ្នកត្រូវបានធានារ៉ាប់រង។
   - មិនមានការចុះបញ្ជីស្របតាមច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា។
5. គ្រោះថ្នាក់នោះកើតឡើង
   - ខណៈអ្នកបើកបរ មានប្រើប្រាស់គ្រឿងញៀន ឬបើកបរស្ថិតនៅក្រោមសារជាតិស្រវឹង (យោងតាមរបាយការណ៍បញ្ជាក់របស់សមត្ថកិច្ចចរាចរណ៍ និងច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា)។
   - **ខណៈអ្នកបើកបរ មិនមានប័ណ្ណបើកបរ ឬមានប័ណ្ណបើកបរដែលខុសប្រភេទយានយន្ត ឬដែលផុតសុពលភាព នៅពេលមានគ្រោះថ្នាក់។ (ប័ណ្ណបើកបរដែលមានសុពលភាពគឺជាប័ណ្ណបើកបរដែល មិនទាន់ផុតសុពលភាព ត្រូវតាមប្រភេទយានយន្ត និងត្រូវតាមច្បាប់ចំពោះអាយុរបស់អ្នកបើកបរ។**
   - **ខណៈដែលលោកអ្នកដោះស្រាយសំណងដោយខ្លួនឯង ហើយគ្មានការយល់ព្រម ឬឯកភាពពីក្រុមដោះស្រាយសំណង ហ្វតតេ ជាមុន។**
6. គ្រោះថ្នាក់នោះកើតឡើងពី
   - សង្គ្រាម ការលុកលុយ បដិវត្ត និងហេតុការណ៍ផ្សេងៗ កូដកម្ម កុប្បកម្ម ឬចលាចលសង្គម។
   - ជាតិវិទ្យុសកម្ម ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ លោហៈ ឬកាកសំណល់ផ្សេងៗ។
   - អំពើភេរវកម្ម សកម្មភាពដែលសមត្ថកិច្ចចុះបង្ក្រាបអំពើភេរវកម្ម និងសកម្មភាពផ្សេងៗ។
   - **ឧក្រិដ្ឋកម្ម ការផាកពិន័យបទល្មើសច្បាប់ចរាចរណ៍ និង សំណងជំងឺចិត្ត។**
7. ភារៈទទួលខុសត្រូវតាមផ្លូវច្បាប់នោះ ជាភារៈទទួលខុសត្រូវដែលលោកអ្នកបានយល់ព្រមក្រោមកិច្ចសន្យាណាមួយ ដែលលោកអ្នកមិនមានភារៈទទួលខុសត្រូវនោះទេ ប្រសិនបើគ្មានកិច្ចសន្យាមួយនោះ។
8. ការខូចខាតនោះកើតឡើង៖
   - ចំពោះឃ្លុបក្រោយនៃយានយន្តដឹកទំនិញធុនតូច (Carryboy) លើកលែងតែឃ្លុបក្រោយនេះមានចែងក្នុងបណ្ណសន្យារ៉ាប់រង ថាបានភ្ជាប់ជាមួយយានយន្តដែលត្រូវបានធានា ។
   - ចំពោះទំនិញនៅលើយានយន្ត ។
   - នៅពេលយានយន្តឈប់នៅមួយកន្លែង ដើម្បីលើកដាក់ទំនិញ ចូលឬពីយានយន្តនោះ (សម្រាប់យានយន្តអាជីវកម្ម)។

**(សម្រាប់ករណីមិនធានាលម្អិត  សូមអានកិច្ចសន្យាធានារ៉ាប់រងរបស់លោកអ្នក។)**

**សម្រាប់ការសាកសួរព័ត៌មានបន្ថែម សូមទាក់ទងទូរស័ព្ទលេខ 📞 012 202 111 / 095 666 518**

បណ្ណសន្យារ៉ាប់រងយានយន្តឯកជន និង យានយន្តអាជីវកម្ម នេះត្រូវបានធានាដោយ **ក្រុមហ៊ុន ហ្វតតេ អ៊ិនសួរ៉ិនស៍ (ខេមបូឌា)**

## នីតិវិធីនៃការទាមទារសំណង

ក្នុងពេលមានហេតុការណ៍គ្រោះថ្នាក់ចៃដន្យ លោកអ្នកត្រូវផ្តល់ដំណឹងភ្លាមៗមកកាន់ ហ្វតតេ តាមរយៈលេខទូរស័ព្ទបន្ទាន់ (24/7) 078 336 999 / 098 793 999 ។
ក្រុមដោះស្រាយសំណងរបស់ ហ្វតតេ នឹងនៅចាំផ្តល់សេវាកម្មជូនលោកអ្នក 24 ម៉ោងជារៀងរាល់ថ្ងៃ (រួមទាំងថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិផ្សេងៗផងដែរ)។

**ដើម្បីសម្រួលដល់ដំណើរការដោះស្រាយសំណង សូមលោកអ្នកផ្តល់ព័ត៌មាន ដូចខាងក្រោម៖**

- ស្លាកលេខយានយន្ត
- អង្គហេតុគ្រោះថ្នាក់
- ពេលវេលា និងទីតាំងកើតហេតុ
- លេខទំនាក់ទំនង

*** សម្រាប់ការទាមទារសំណងលើការបាត់បង់ ដោយសារចោរកម្ម (ចោរគាស់ ចោរលួច ចោរប្លន់) យានយន្ត លោកអ្នកត្រូវផ្តល់ដំណឹងភ្លាមៗ (ដាក់ពាក្យបណ្តឹង) ទៅកាន់ អាជ្ញាធរមានសមត្ថកិច្ចប្រចាំតំបន់កើតហេតុ។**

**ចំណាំ**

◆ ពេលមានគ្រោះថ្នាក់ លោកអ្នកមិនត្រូវទទួលកំហុស ឬសន្យាធ្វើសំណងឬបង់ប្រាក់អ្វីមួយ ដោយគ្មានការណែនាំឬព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពី ហ្វតតេ ឡើយ។ បើមិនដូច្នោះ លោកអ្នកអាចនឹងមិនទទួលបានសំណងពីការធានាក្នុងបណ្ណសន្យារ៉ាប់រង នេះឡើយ។

◆ លោកអ្នកត្រូវផ្តល់កិច្ចសហការណ៍ជាមួយ ហ្វតតេ ក្នុងការទាមទារសំណងនៃ គ្រោះថ្នាក់នីមួយៗ។

**សម្រាប់ការជូនដំណឹងពីការទាមទារសំណង**
សូមទំនាក់ទំនងទៅកាន់ទូរស័ព្ទបន្ទាន់ (24/7)  លេខ

**RED Team | 078 336 999 | 098 793 999**

ស្កេនទីនេះ ដើម្បីទាញយកបែបបទទាមទារសំណង និងបណ្ណសន្យារ៉ាប់រងលម្អិត រថយន្តឯកជន

ស្កេនទីនេះ ដើម្បីទាញយកបែបបទទាមទារសំណង និងបណ្ណសន្យារ៉ាប់រងលម្អិត រថយន្តអាជីវកម្ម